# ក្រុមហ៊ុន ជីនវីន អ៊ិនដាស្ទ្រី (ខេមបូឌា) ខូអិលធីឌី

GINWIN INDUSTRY ( CAMBODIA ) CO., LTD

## កិច្ចព្រមព្រៀង

ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល២ខែ គឺ
ចាប់ពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ ដល់ថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ២០២០

ថ្ងៃសុក្រ ១៤រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ វេលាម៉ោងប្រាំបួនព្រឹក មានកិច្ចប្រជុំមួយនៅ ក្រុមហ៊ុន ជីនវីន អ៊ិនដាស្ទ្រី (ខេមបូឌា) ខូអិលធីឌី មានអាសយដ្ឋានស្ថិតនៅភូមិព្រៃចាស់ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដែលមានចំនួនកម្មករសរុបចំនួន១៧៥៨នាក់ (ស្រី១៦៨០នាក់)មាននាយកឈ្មោះ WANG MENGJIN ជនជាតិចិន ជាក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ ដែលមានលោក MIAO XUENAN ជាតំណាងនាយកប្រចាំក្រុមហ៊ុនបានចូលរួមប្រជុំពិភាក្សាលើករណី ស្តីពីការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតយៈពេល២ខែ។

ជាកិច្ចចាប់ផ្តើមលោក MIAO XUENAN ជាប្រធានអង្គប្រជុំបានបើកកិច្ចប្រជុំនិងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅ ដល់អស់លោក លោកស្រីដែលបានអញ្ជើញចូលរួមប្រជុំថ្ងៃនេះ បន្ទាប់មកលោកប្រធាន អង្គប្រជុំមានមតិសម្របសម្រួលអំពី ករណីខាងលើ និងពន្យល់ពីមូលហេតុដោយសារតែក្រុមហ៊ុនគ្មានការបញ្ជាទិញ និងដោយសារម្ចាស់ទំនិញបានពន្យាពេលទិញទំនិញក្នុងអំឡុងពេលផ្ទុះមេរោគ ឆ្លងជាសាកលកូវីដ-១៩ ដូចនេះក្រុមហ៊ុន ជីនវីន អ៊ិនដាស្ទ្រី (ខេមបូឌា) ខូអិលធីឌី និងកម្មករនិយោជិតទាំងអស់ បានព្រមព្រៀងគ្នាដូចខាងក្រោមៈ

១-ឯកភាពព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន៦២៤នាក់ (ស្រី៥៨២នាក់) រយៈពេល២ខែ ដោយគិតចាប់ពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ ដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ ។

២-ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះភាគីទាំងពីរបានឯកភាពអនុវត្តន៍តាមសេចក្តីណែនាំរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ខេត្តកណ្តាលថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០

**បានឃើញនិងឯកភាព**

**តំណាងកម្មករនិយោជិត**

ជា ជួន  ឈិត ធារ៉ា  សុន លីមហុង  គីម ស៊ុនរី

ឃិន សុខា  ហៃ ស្រីលក្ខ  អ៊ឹម គីមសួរ

**តំណាងក្រុមហ៊ុន**

Mr.Miao xuenan